# មេរៀនទី ៤១: ការរៀបការរបស់អ៊ីសាកជាមួយរេបិកា

## លោកុប្បត្តិ ២៤

**គោលបំណង៖** ព្រះជួយយើងឲ្យធ្វើការជ្រើសរើសនៅក្នុងជីវិត

**ខគម្ពីរចងចាំ៖ យេរេមា ២៩:១១** *"ដ្បិតព្រះយេហូវ៉ាមានព្រះបន្ទូលថា អញស្គាល់សេចក្ដីដែលអញគិតពីដំណើរឯងរាល់គ្នា មិនមែនគិតធ្វើសេចក្ដីអាក្រក់ទេ គឺគិតឲ្យបានសេចក្ដីសុខវិញ ដើម្បីដល់ចុងបំផុតឲ្យឯងរាល់គ្នាបានសេចក្ដីសង្ឃឹម។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

អ្នកបម្រើរបស់អ័ប្រាហាំមានកាតព្វកិច្ចដ៏លំបាក ដូច្នេះហើយគាត់បានសុំប្រាជ្ញា និងជំនួយពីព្រះ។ ពួកយើងដែលជាអ្នកបង្រៀនកូនៗរបស់ព្រះក៏មានកាតព្វកិច្ចលំបាកដែរ! នៅពេលអ្នករៀបចំបង្រៀននៅសប្ដាហ៍នេះ សូមទូលសុំព្រះអម្ចាស់ជួយដល់អ្នក។ សូមទូលសូមទៅព្រះជាម្ចាស់ឲ្យបានច្បាស់លាស់តាមដែលអាចធ្វើបាន ហើយរង់ចាំដោយការទុកចិត្តដល់ទ្រង់ចំពោះការណែនាំ និងការបង្ហាញផ្លូវរបស់ព្រះអង្គ!

**ចំរៀង៖** ១. ព្រះអម្ចាស់យើងល្អណាស់ ២.តើអ្នកណាជាម្ចាស់នៃខ្ញុំ ៣. ខ្ញុំថ្វាយបង្គំទ្រង់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត** «ខ្ទឹបផ្កា»



- ចែកកុមារជា២ក្រុម
- ជ្រើសរើសមេក្រុមម្នាក់សំរាប់ក្រុមនិមួយៗ
- មេក្រុមត្រូវដាក់ឈ្មោះថ្មីឲ្យសមាជិកក្រុមរបស់ខ្លួន
- បន្ទាប់មកមេក្រុមទាំង ២ ប៉ាវ អ្នកដែលឈ្នះនឹងមានសិទ្ធិបិទភ្នែកកូនក្រុមនៃក្រុមម្ខាងទៀតចាញ់
- រួចមេក្រុមហៅកូនក្រុមខ្លួនមកទះបាតដៃអ្នកដែលត្រូវបិទភ្នែកនោះហើយឲ្យគេទៅកន្លែងដើមវិញអង្គុយធ្វើដូចធម្មតាហើយសមាជិកក្រុមទាំងអស់ទះដៃព្រមគ្នា។
- មេក្រុមបើកភ្នែកអ្នកដែលត្រូវបិទនោះ ហើយឲ្យគាត់ទាយថា អ្នកណាជាអ្នកទះបាតដៃគាត់
- បើគាត់ទាយត្រូវអ្នកនោះត្រូវនៅជាមួយក្រុមរបស់គាត់ តែបើទាយខុសគាត់ត្រូវនៅជាមួយក្រុមដែលទះបាតដៃគាត់វិញ។

**៤. ការណែនាំមេរៀន**

រឿងក្នុងព្រះគម្ពីរថ្ងៃនេះ យើងនិងឮពីបុរសម្នាក់ដែលបានធ្វើការសំរេចចិត្តដ៏ពិបាកមួយ។ ក្នុងជំនាន់របស់លោកអ័ប្រាហាំ ឪពុកម្ដាយជាអ្នកជ្រើសរើសប្ដី ឬប្រពន្ធសម្រាប់កូនៗរបស់ពួកគេ។ លោកអ័ប្រាហាំចង់ធ្វើឱ្យប្រាកដថា

កូនប្រុសរបស់គាត់អ៊ីសាកនឹងបានរៀបការជាមួយនារីម្នាក់ ដែលមានប្រវត្តិគ្រួសារល្អនិងកោតខ្លាចដល់ព្រះដូចគាត់និងគ្រួសាររបស់គាត់ដែរ។ តែវាជារឿងដែលគួរឲ្យសោកស្ដាយ ដែលនារីវ័យក្មេងទាំងនោះកំពុងតែរស់នៅក្នុងស្រុកដែលអ័ប្រាហាំបានចាកចេញជាច្រើនឆ្នាំកន្លងមកហើយ។ ដូច្នេះអ័ប្រាហាំ បានបញ្ជូនអ្នកបំរើដែលគាត់ទុកចិត្តម្នាក់ឱ្យត្រឡប់ទៅប្រទេសកំណើតរបស់គាត់នោះវិញដើម្បីរកប្រពន្ធល្អឥតខ្ចោះឱ្យអ៊ីសាក។ តើអ្នកគិតថាអ្នកបំរើរបស់គាត់អាចនឹងរកបានប្រពន្ធល្អឥតខ្ចោះសំរាប់អ៊ីសាកដែរឬទេ?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

**(សូមបោះពុម្ពផ្ទាំងរូបភាព “ តើអ្នកណាជាប្រពន្ធល្អឥតខ្ចោះសំរាប់អ៊ីសាក? ” ហើយប្រើរូបភាពនោះ )**

តាមការបង្គាប់របស់អ័ប្រាហាំ អ្នកបំរើបានទៅស្វែងរកប្រពន្ធឲ្យអ៊ីសាក។ ពេលអ្នកបំរើទៅដល់ស្រុកដែលអ័ប្រា-ហាំបានចាកចោលនោះ គាត់ដឹងថាគាត់ត្រូវការជំនួយក្នុងការសម្រេចចិត្តដ៏សំខាន់មួយ។ ពីព្រោះមាននារីៗជាច្រើនដែលរស់នៅក្នុងស្រុកនោះ ហើយគាត់ត្រូវការជ្រើសរើសយកតែនារីម្នាក់ដែលល្អបំផុតនៅក្នុងចំណោមពួកគេ។

នៅក្នុងរូបភាព នារីៗទាំងអស់ដែលស្លៀកសម្លៀកបំពាក់ពណ៌ខៀវ មានប្រវត្តិគ្រួសារស្រដៀងនឹងគ្រួសាររបស់លោកអ័ប្រាហាំដែរ។ ដូច្នេះសម្រាប់នារីណាដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការកំណត់នោះនឹងត្រូវគូសខ្វែងចេញ។ យើងក៏អាចគូសខ្វែងលើរូបនារីផ្សេងទៀតដែលមិនបានស្លៀកសម្លៀកបំពាក់ពណ៌ខៀវដែរ។

អ្នកបំរើក៏បានអធិស្ឋាន! សូមចាំថានារីដែលគាត់នឹងជ្រើសរើសត្រូវតែជាមនុស្សម្នាក់ដែលជាប់ទាក់ទងទៅនឹងប្រវត្តិគ្រួសាររបស់អ័ប្រាហាំ ដើម្បីឲ្យអ៊ីសាក និងនារីម្នាក់នោះអាចថ្វាយបង្គំព្រះជាម្ចាស់តែមួយជាមួយគ្នា ហើយបង្រៀនកូនៗអំពីផ្លូវរបស់ព្រះ។ នារីដែលមានលក្ខណៈសម្បត្តិផ្សេងៗទៀតនឹងមិនត្រូវបានជ្រើសរើសធ្វើជាប្រពន្ធរបស់អ៊ីសាកឡើយ។

អ្នកបំរើនោះស្រេកទឹកណាស់ គាត់បានសុំឲ្យព្រះដឹកនាំផ្លូវគាត់ទៅរកនារីណាដែលមានចិត្តល្អ និងចេះជួយអ្នកដ៏ទៃ ហើយនាងនឹងផ្ដល់ទឹកឲ្យគាត់នៅពេលគាត់សុំ។ នៅលើផ្ទាំងរូបភាពរបស់យើង យើងអាចគូសខ្វែងនរណាម្នាក់ដែលមិនមានកាន់ក្អមទឹក។

អ្នកបំរើបានសុំឲ្យព្រះបង្ហាញផ្លូវគាត់ទៅរកស្ត្រីម្នាក់ ដែលមានទឹកចិត្តល្អពិតប្រាកដ ហើយនឹងឲ្យទឹកដល់សត្វអូដ្ឋរបស់គាត់ផឹកដែរ។ ព្រះបាននាំអ្នកបម្រើនោះឲ្យទៅជួបនឹងរេបិកា។ នៅពេលនាងបានឲ្យទឹកទៅគាត់ និងអូដ្ឋរបស់គាត់ផឹក អ្នកបំរើបានសួរអំពីគ្រួសាររបស់នាង។ រេបិកាមានប្រវត្តិគ្រួសារល្អ ហើយត្រូវនឹងលក្ខខណ្ឌដែលអ័ប្រាហាំចង់បាន។ អ្នកបំរើបានដឹងថា ព្រះបានឆ្លើយតបតាមការអធិស្ឋានរបស់គាត់ហើយ។ ចំណែកឯក្រុមគ្រួសាររបស់រេបិកាក៏បានទទួលស្គាល់ថានេះជាការបង្ហាញផ្លូវរបស់ព្រះដែរ ហើយពួកគាត់ក៏បានអនុញ្ញាតឱ្យនាងទៅជាមួយនឹងអ្នកបំរើដើម្បីទៅធ្វើជាប្រពន្ធរបស់អ៊ីសាក។

នៅពេលដែលយើងសុំការបង្ហាញផ្លូវពីព្រះ ទ្រង់សព្វព្រះទ័យនឹងប្រាប់យើង។ យើងបង្ហាញការគោរពចំពោះព្រះដោយជឿថា ផែនការរបស់ព្រះគឺប្រសើរជាងផែនការរបស់យើង។ សូមកុំភ្លេចថាព្រះមានផែនការសំរាប់យើងម្នាក់ៗ ហើយទ្រង់ជួយតម្រង់ផ្លូវនៅក្នុងជីវិតរស់នៅរបស់យើង។

## ៦. សំនួរពិភាក្សា

១. តើលោកអ័ប្រាហាំបានចាត់អ្នកណាឲ្យរកប្រពន្ធឲ្យអ៊ីសាក ?*គឺអ្នកបំរើរបស់គាត់*

២. តើអ្នកបំរើបានធ្វើអ្វីមុនពេលបានជួបរេបិកា? *គាត់បានអធិស្ឋាន ហើយគាត់បានទុកចិត្តលើព្រះ ព្រះបានជួយគាត់ឲ្យជួបមនុស្សម្នាក់ដែលត្រូវនឹងតំរូវការរបស់គាត់*

៣. នៅពេលដែលប្អូនជួបការលំបាកនៅក្នុងជីវិត តើប្អូននឹងធ្វើអ្វី? *សួរឪពុកម្តាយ សួរព្រះ*

## ៧. ខគម្ពីរចងចាំ យេរេមា ២៩:១១

- ជួយកុមារឲ្យចាំខគម្ពីរតាមរយៈការធ្វើសំលេងអេកូហ្គេមដោយឲ្យកុមារថាតាមគ្រូនៅឃ្លាចុងក្រោយដដែលៗច្រើនដង
- ឧទាហរណ៍៖ ដ្បិតព្រះយេហូវ៉ាមានព្រះបន្ទូលថា ថាៗៗៗៗ

## ៨. ហាត្ថកម្ម

**ជម្រើសទី ១ «បត់ក្រដាសឱ្យចេញជារូបផ្សេងៗ»**

ការបត់ចាបក្រដាស(ក្រដាសជារាងការ៉េមួយសន្លឹកសម្រាប់កុមារម្នាក់)
(គ្រូះសូមស្វែងយល់ ពីរបៀបបត់ចាបក្រដាសតាមរយៈ link ខាងក្រោមនេះ៖
Origami Bird - https://www.youtube.com/watch?v=NdC4NE-eT9E)
យើងមានក្រដាសរាងការ៉េនៅទីនេះ។ តើយើងអាចធ្វើអ្វីជាមួយនឹងក្រដាសនេះបាន?(ទុកឱ្យកុមារជាអ្នកឆ្លើយ) ដូចគ្នាដែរព្រះមានផែនការសម្រាប់យើងម្នាក់ៗ ហើយយើងក៏មានផែនការសម្រាប់ក្រដាសរាងការ៉េមួយនេះដែរ។ ប្រសិនបើកូនធ្វើតាមការណែនាំនេះ ចុងបញ្ចប់កូនៗនឹងទទួលបានលទ្ធផលដ៏ពិសេសបំផុត។

**ជម្រើសទី២៖** ឲ្យកុមារផាត់ពណ៌លើរូបភាពដែលមានខគម្ពីរចងចាំ

## ៩. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១០. អធិស្ឋាន *(សូមនាំកុមារអធិស្ឋានបិទ)*

# មេរៀនទី២៨៖ តើនរណាជាប្រពន្ធដ៏ល្អរបស់អ៊ីសាក់?












សូមសរសេរខគម្ពីរចងចាំ: ________________________________

________________________________________

________________________________________